ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន
និង សង្គ្រោះជនពិការដោយសារមីន

លេខ : ៥៥០ /អន/អជម/២០២៥

# សេចក្ដីណែនាំ
# ស្ដីពី
# ការពង្រឹងវិធានការសុវត្ថិភាពចំពោះប្រតិបត្តិការសកម្មភាពមីន និងការអប់រំផ្សព្វផ្សាយការយល់ដឹងពីយុទ្ធភណ្ឌគ្រឿងផ្ទុះ អំឡុងពេលឈ្លានពានរបស់យោធាថៃមកលើកម្ពុជា

ចាប់តាំងពីការចាប់ផ្ដើម នៃសកម្មភាពឈ្លានពានខុសច្បាប់របស់យោធាថៃ មកលើកម្ពុជា ដោយលើកទី១ ពីថ្ងៃទី២៤ ដល់ថ្ងៃ២៨ ខែកក្កដា ឆ្នាំ២០២៥ និងលើកទី២ ពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥ មកទល់ពេលបច្ចុប្បន្ន យោធាថៃបានប្រើប្រាស់យុទ្ធោបករណ៍ធុនធ្ងន់គ្រប់ប្រភេទមកលើតំបន់ស៊ីវិល និងបានបំពានការអនុវត្តបទឈប់បាញ់នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ សេចក្ដីថ្លែងការណ៍រួមទីក្រុងគូឡាឡាំពួរ ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥ ធម្មនុញ្ញអង្គការសហប្រជាជាតិ ធម្មនុញ្ញអាស៊ាន និងរំលោភលើគោលការណ៍ជាមូលដ្ឋាននៃច្បាប់អន្តរជាតិ។

ការឈ្លានពានដោយប្រើប្រាស់យុទ្ធោបករណ៍ទាំងនោះ បានបណ្ដាលឱ្យប្រជាជនស៊ីវិលស្លាប់ និងរបួសជាច្រើននាក់ បំផ្លិចបំផ្លាញទ្រព្យសម្បត្តិនិងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ មណ្ឌលសុខភាព សាលារៀន វត្តអារាម ប្រាសាទបុរាណ និងបានបង្ខំឱ្យប្រជាជនប្រមាណជាង ២០ម៉ឺនគ្រួសារ ត្រូវជម្លៀសចេញពីលំនៅដ្ឋានទៅកាន់ទីតាំងសុវត្ថិភាពជាច្រើនកន្លែង តាមបណ្ដាខេត្តនានា។ មិនត្រឹមតែប៉ុណ្ណោះ ការឈ្លានពាននេះ *បណ្ដាលឱ្យប៉ះពាល់ដល់ប្រតិបត្តិការបោសសម្អាតមីនមនុស្សធម៌ ពិសេសបុគ្គលិកបោសសម្អាតមីនប្រមាណជាង ៩០០ នាក់ ព្រមទាំងក្រុមគ្រួសារ ដែលត្រូវធ្វើការភៀសខ្លួនទៅកាន់ទីមានសុវត្ថិភាព។*

ខណៈដែល **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បាននិងកំពុងខិតខំប្រឹងប្រែងដោះស្រាយបញ្ហា បង្កដោយការឈ្លានពានរបស់យោធាថៃ ប្រកបដោយភាពម៉ឺងម៉ាត់ ស្មារតីស្នេហាជាតិខ្ពស់ និងរក្សាឱ្យបាននូវឧត្តមផលប្រយោជន៍ជាតិ ដើម្បីនាំមកនូវសន្តិភាព សុខសុវត្ថិភាព និងសុខដុមរមនា ជូនប្រជាជន និងប្រទេសជាតិ អាជ្ញាធរមីន សូមធ្វើការណែនាំដល់ប្រតិបត្តិករសកម្មភាពមីន ដូចមានខាងក្រោម ដើម្បីបង្ការ និងទប់ស្កាត់គ្រោះថ្នាក់ដែលអាចកើតមានជាយថាហេតុដល់បុគ្គលិកដែលកំពុងបម្រើការងារក្នុងវិស័យសកម្មភាពមីន ក៏ដូចជាប្រជាជនភៀសសឹកក្នុងអំឡុងពេល នៃការឈ្លានពានរបស់យោធាថៃ៖

១- បន្តយកចិត្តទុកដាក់ខ្ពស់បំផុតចំពោះសុវត្ថិភាពបុគ្គលិកបោសសម្អាតមីន និងមិនត្រូវអនុញ្ញាតឱ្យបុគ្គលិកបន្តការងារក្នុងស្ថានភាពប្រឈមនឹងការគ្រោះថ្នាក់

២- បន្តយកចិត្តទុកដាក់ និងផ្តល់ការគាំទ្រដល់បុគ្គលិកបោសសម្អាតមីន ដែលមានក្រុមគ្រួសារកំពុងរស់នៅក្នុងតំបន់ប្រឈមនឹងការគ្រោះថ្នាក់ ឬតំបន់ជនភៀសសឹកនានា

៣- ផ្អាករាល់ប្រតិបត្តិការស្រាវជ្រាវ បោសសម្អាត និងសកម្មភាពអប់រំផ្សព្វផ្សាយការយល់ដឹងពីយុទ្ធភណ្ឌគ្រឿងផ្ទុះ នៅតាមតំបន់ប្រឈមនឹងការគ្រោះថ្នាក់ ដោយសារសកម្មភាពឈ្លានពានរបស់យោធាថៃ ដើម្បីរក្សាសុវត្ថិភាពជូនដល់បុគ្គលិកបោសសម្អាតមីន

៤- ស្នើសុំជាបន្ទាន់មកអាជ្ញាធរមីន ចំពោះការផ្លាស់ប្តូរផែនការបោសសម្អាតចម្ការមីន ក្នុងករណីចម្ការមីននោះ ស្ថិតក្នុងតំបន់ប្រឈមនឹងការគ្រោះថ្នាក់ ដោយសារសកម្មភាពឈ្លានពានរបស់យោធាថៃ

៥- បន្តរៀបចំកម្មវិធីអប់រំផ្សព្វផ្សាយការយល់ដឹងអំពីគ្រោះថ្នាក់ដោយសារមីន គ្រាប់បែកចង្កោម និងយុទ្ធភណ្ឌគ្រឿងផ្ទុះផ្សេងទៀត ដែលបាញ់និងទម្លាក់ដោយយោធាថៃ ជូនប្រជាជនដែលកំពុងស្នាក់នៅតាមទីតាំងសុវត្ថិភាព ដើម្បីចៀសវាងគ្រោះថ្នាក់ពីសំណល់ជាតិផ្ទុះទាំងនោះ នៅពេលប្រជាជនត្រលប់ទៅកាន់មូលដ្ឋានរបស់ខ្លួនវិញ នៅពេលប្រក្រតីភាព និងសន្តិភាពវិលត្រលប់ដូចដើម

៦- បន្តផ្តល់កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ ជូនចំពោះអាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ ក្នុងការដាក់ស្លាកសញ្ញាគ្រោះថ្នាក់ នៅទីតាំងដែលមានយុទ្ធភណ្ឌគ្រឿងផ្ទុះ ដែលបានបាញ់ និងទម្លាក់ដោយយោធាថៃ ឬយកទៅរក្សាទុកនៅទីតាំងមានសុវត្ថិភាព(សម្រាប់ជាភស្តុតាង) ឬកម្ទេចចោលតាមការចាំបាច់ ដើម្បីធានាសុវត្ថិភាពជូនប្រជាជន និងមន្ត្រី-បុគ្គលិកមូលដ្ឋាន ព្រមទាំងដើម្បីចៀសវាងគ្រោះថ្នាក់ជាយថាហេតុ និងផ្តល់កិច្ចសហការ តាមសំណូមពររបស់អាជ្ញាធរមូលដ្ឋាន

៧- បន្តរក្សាកិច្ចសហការល្អជាមួយគណៈកម្មាធិការសកម្មភាពមីនខេត្ត និងក្រុមការងារសកម្មភាពមីនខេត្ត ក្នុងសកម្មភាពបោសសម្អាត សកម្មភាពអប់រំផ្សព្វផ្សាយការយល់ដឹងពីយុទ្ធភណ្ឌគ្រឿងផ្ទុះ និងកិច្ចសង្គ្រោះជនរងគ្រោះ

៨- បន្តតាមដានការវិវត្តនៃសកម្មភាពវាយប្រហារដោយយោធាថៃជាប្រចាំ ពីប្រភពព័ត៌មានផ្លូវការផ្តល់ដោយក្រសួង-ស្ថាប័នជាតិពាក់ព័ន្ធ ដើម្បីអនុវត្តសកម្មភាពខាងលើប្រកបដោយប្រសិទ្ធភាព។

អាស្រ័យដូចបានណែនាំខាងលើ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រីប្រធាន អង្គភាពនៃប្រតិបត្តិករសកម្មភាពមីនទាំងអស់ ចូលរួមសហការនិងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ សុក្រ ៧កើត ខែ បុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ២០២៥

**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស**

**អនុប្រធានទី១**

អាជ្ញាធរមីន CMAA

**បណ្ឌិត លី ធុជ**

**<u>ចម្លងជូន៖</u>**

- រដ្ឋបាលខេត្តពាក់ព័ន្ធ
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ «ដើម្បីសហការ»
- គណៈកម្មាធិការសកម្មភាពមីនរាជធានី-ខេត្ត «ដើម្បីសហការ»
- គ្រប់ប្រតិបត្តិករសកម្មភាពមីន «ដើម្បីអនុវត្ត»
- ឯកសារ កាលប្បវត្តិ